តុលាការកំពូល                    ជាតិ   សាសនា   ព្រះមហាក្សត្រ

សភាផ្នែករដ្ឋប្បវេណី                    *******

សំណុំរឿងរដ្ឋប្បវេណី

លេខ ២៧                    នាមនាមប្រជារាស្ត្រខ្មែរ

ចុះថ្ងៃទី២៩ខែមករាឆ្នាំ១៩៩៩                    តុលាការកំពូល

សាលដីកា

លេខ : ១៨៦

ចុះថ្ងៃទី១៤ខែកញ្ញាឆ្នាំ២០០០

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ខិត មុន្នី ប្រធាន

២- លោក ប៉ែន ស៊ុន ចៅក្រម

៣- លោក ជីវ កេង ចៅក្រម

៤- លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៥- លោក សោម សិរីវឌ្ឍ ចៅក្រម

ក្រឡាបញ្ជី

លោកស្រី ភួង ចន្ថា

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៧៨០ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ទុន សារ៉ាង ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្ហាត់សិល្បៈ មានទីលំនៅផ្ទះលេខ ១៦៤ ផ្លូវ ១៩ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ទុន សុខ " ស " ម្តាយឈ្មោះ ពៅ ភួង " ស " ។

មានមេធាវី លោក ទូត លុច ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ឈន ម៉ាលី ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ ១៦៤CEo ផ្លូវ ១៩ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុក ឈន ស៊ុន " ស " ម្តាយឈ្មោះ អ៊ូ គុណ " ស " ។

មានមេធាវី លោក ហែម វ៉ិន

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំឱ្យរុះរើសំណង់តយ៉ាកជាប់ជញ្ជាំងផ្ទះ

បានឃើញបណ្តឹងសាទុក្ខលេខ ៥៣៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់លោក ទុន សារ៉ាង បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ៤០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៧ ចុះថ្ងៃទី២៩ ខែមករាឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៧_៨_៩៨ របស់ដើមចោទ អ្នកស្រី ឈន ម៉ាលី ប្ដឹងសុំឱ្យឈ្មោះ ទុន សារ៉ាង រុះរើសំណង់តយ៉ាកជាប់ជញ្ជាំងផ្ទះខ្លួន ចេញដោយហេតុថា ឈ្មោះទុន សារ៉ាង បានរំលោភសង់សំយ៉ាប លើជញ្ជាំងផ្ទះរបស់ខ្លួន ធ្វើឱ្យបាំងខ្យល់ បាំងបង្អួចគ្មានពន្លឺចេញចូល ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៧ " ក " ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ចំពោះមុខគូក្ដី ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១៧_៨_១៩៩៨ និង សំណូមពររបស់ឈ្មោះ ឈន ម៉ាលី ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បង្គាប់ឱ្យឈ្មោះ ទុន សារ៉ាង រុះរើសំណង់តយ៉ាប ទំហំ ៥ម×២,៥០ម ជាប់ជញ្ជាំងផ្ទះលេខ ១៦៤CE០ និង យកទ្រព្យសម្បត្តិចេញ ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃសាលក្រមនេះចូលស្ថាពរ ហើយថែរក្សាកន្លែងនោះ ទុកដូចសភាពដើម ។

៣- ឱ្យឈ្មោះ ទុន សារ៉ាង បង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្លឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល បូករួម៧០០០រៀល ប្រាក់នេះកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទ បានបង់ទុកជាស្រេច ។

កាលបើផុតបណ្ដឹងឧទ្ធរណ៍ ហើយបង្គាប់ឱ្យឈ្មោះ ទុន សារ៉ាង សងប្រាក់ ៧០០០រៀល ឱ្យទៅដើមចោទវិញ តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ។

៤- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី សំរេចបើកផ្លូវឧទ្ធរណ៍ ក្នុងរយៈពេលពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១២ "ក" ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ១៩៩៩ របស់អ្នកស្រី ទុន សារ៉ាង ដែលប្ដឹងជំទាស់នឹងសាលក្រមលេខ ១៧ "ក" ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ១៩៩៩ លើវិនិច្ឆ័យសេចក្ដីទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៧៨០ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ចំពោះមុខគូក្ដី ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២_០៤_៩៩ របស់ឈ្មោះ ទុន សារ៉ាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៧ "ក" ចុះថ្ងៃទី ០៧_០៤_៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្ដី ជាន់សាលាឧទ្ធរណ៍ ១៣០០០៛ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្លឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ , ដីកាកោះ ៥០០០៛ , អាជ្ញាធរតុលាការ ៥០០០៛ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៥៣៤ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៩ របស់អ្នកស្រី ទុន សារ៉ាង

បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៧៨០ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ១៩-០៥-២០០០ របស់លោក ទុន សារ៉ាង

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។
- សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ទុន សារ៉ាង ចុងចម្លើយ និងម្ចាស់បណ្តឹងសាទុក្ខ នាពេលសវនាការបញ្ជាក់ថា : តុលាការក្រុង និងសាលាឧទ្ធរណ៍ សំរេចសេចក្តីឱ្យខ្ញុំរុះរើសំយ៉ាបផ្ទះនេះ មិនបានចុះមកពិនិត្យមើលដល់ទីកន្លែងទេ ។ ហេតុនេះទើបខ្ញុំមកតុលាការកំពូល ព្រោះថា ដើមចោទគ្មានអំណះអំណាងណាថា ដីនៅពីមុខផ្ទះខ្ញុំជាម្ចាស់កម្មសិទ្ធិឡើយ ហើយទោះបីជាមានប្លង់កម្មសិទ្ធិរបស់ខ្ញុំមានក៏ដោយ ក៏បានកំណត់ត្រឹមតែព្រំប្រទល់ផ្ទះរបស់ខ្ញុំតែប៉ុណ្ណោះ ពុំមានកំណត់ដល់ដីនៃផ្ទះខ្ញុំទេ ។ ដោយពាក្យបណ្តឹងប្រជាជន ១៧គ្រួសារ បញ្ជាក់ច្បាស់ និង មានអាងទឹកជាភស្តុតាង ។ ចំណែកសំយ៉ាបផ្ទះ ដែលខ្ញុំបានតយ៉ាបចេញពីផ្ទះ ឈន ម៉ាលី មានទំហំ បណ្តោយ ៥ម ទទឹង ៣ម នោះក៏ពុំមានប៉ះពាល់ដល់សុខភាពរបស់គ្រួសារ ឈន ម៉ាលី ដែរ ព្រោះថា សំយ៉ាបនោះពុំមានបិទបាំងជញ្ជាំងអ្វីឡើយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឈន ម៉ាលី ដើមចោទ និង ចុងបណ្តឹងសាទុក្ខ នាពេលសវនាការបញ្ជាក់ថា : ដីនេះ ជាដីចំណីផ្ទះរបស់ខ្ញុំពិតប្រាកដ ដោយមានប្លង់ត្រឹមត្រូវតាមច្បាប់ ។ ចំពោះអាងទឹក ខ្ញុំមិនទាមទារអ្វីទេ ខ្ញុំមករស់នៅផ្ទះនេះក្នុងឆ្នាំ ៨១ ទុន សារ៉ាង មករស់នៅក្រោយខ្ញុំ ទុន សារ៉ាង សង់រោងនៅឆ្នាំ ៩៣ ហេតុដូច្នេះ ខ្ញុំឱ្យគាត់រុះរើយ៉ាបនេះ ចេញពីដីខ្ញុំ ព្រោះវាធ្វើឱ្យប៉ះពាល់ដល់ផាសុខភាពគ្រួសារខ្ញុំ គ្មានពន្លឺចេញ-ចូល ក្នុងផ្ទះ ។

សេចក្តីសន្និដ្ឋានមេធាវី ទួត លុច លើកឡើងថា: ចំពោះដីដែលកូនក្តី ខ្ញុំបាទសង់រោងនេះ គឺជាដីសាធារណៈ ព្រោះមានប្រជាជន ១៧គ្រួសារ ប្រើប្រាស់រួមតាំងពីឆ្នាំ ១៩៧៩ ។ នៅក្នុងរឿងក្តីនេះ អ្នកស្រី ឈន ម៉ាលី ប្តឹងឱ្យកូនក្តីខ្ញុំបាទរុះរើជញ្ជាំងដែលសង់ជាប់ជញ្ជាំងផ្ទះរបស់គាត់ ធ្វើឱ្យបិតរន្ធខ្យល់ និង បាំងពន្លឺផ្ទះគាត់ កូនក្តីខ្ញុំបាទសុខចិត្តរុះរើចេញ១ ,៥០ម ចេញពីជញ្ជាំងអ្នកស្រី ឈន ម៉ាលី ហេតុដូច្នេះ តុលាការមេត្តាពិនិត្យពិចារណារកយុត្តិធម៌ឱ្យកូនក្តីខ្ញុំបាទផង ។

សេចក្តីសន្និដ្ឋានរបស់មេធាវី ហែម វុន លើកឡើងថា: អ្នកស្រី ឈន ម៉ាលី បានមករស់នៅផ្ទះនេះតាំងពីឆ្នាំ ៨១ មានសាក្សីដឹងឮ ម្យ៉ាងទៀត អ្នកស្រី ឈន ម៉ាលី មានបណ្ណកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ មិនមែនជាដីសាធារណៈនោះទេ ព្រោះថា អ្នកស្រី ទុន សារ៉ាង បានសង់សំណង់ខុសច្បាប់នគរូបនីយកម្ម ដូចមានកំណត់ហេតុបញ្ជាក់របស់សង្កាត់ ខណ្ឌ និង មន្ទីររៀបចំក្រុង និងសំណង់បញ្ជាក់ជូនតុលាការស្រាប់ ។ ហេតុដូច្នេះ ខ្ញុំបាទសុំសំណូមពរ ឱ្យតុលាការកំពូល មេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីនៃគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៩៣៤ ចុះថ្ងៃទី០១-១២-១៩៩៩ របស់អ្នកស្រី ទុន សារ៉ាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយកមកជំនុំជំរះបានតាមមាត្រា ១៤នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់អ្នកស្រី ទុន សារ៉ាង ក្នុងសារណា ចុះថ្ងៃទី១៩-៥-២០០០ ថា ទោះបីខ្លួនបានសយ៉ាបចេញពីជញ្ជាំងផ្ទះរបស់ឈ្មោះឈន ម៉ាលី ក៏ដោយ តែដីចំហៀងផ្ទះនេះ អ្នកស្រីឈន ម៉ាលី ពុំមានសិទ្ធិគ្រប់គ្រងឡើយ ព្រោះជាដីសម្ភហភាព ហើយសំយ៉ាបទៀតសោត ក៏ពុំមានប៉ះពាល់ផាសុខភាព ដល់គ្រួសារ ឈន ម៉ាលី ដែរ នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

+ សេចក្តីសំរេច របស់តុលាការក្រុងភ្នំពេញ ដែលសាលាឧទ្ធរណ៍តម្កល់ទុកជាបានការនោះ ពុំមានចែងអំពីកម្មសិទ្ធិរបស់អ្នកស្រី ឈន ម៉ាលី លើដីចំហៀងផ្ទះលេខ ១៦៤E០ ទេ គឺសំរេចតាមតែកម្មវត្ថុបណ្តឹងរបស់អ្នកស្រី ឈន ម៉ាលី តែប៉ុណ្ណោះ ។

+ លិខិតលេខ ២៨១ របក ចុះថ្ងៃទី ០៦-១០-៩៨ របស់សាលាខណ្ឌ ដូនពេញ និង លិខិតលេខ ២៦៧ រកសណសជ ចុះថ្ងៃទី ២៩-០១-៩៩ របស់មន្ទីររៀបចំក្រុង និងសំណង់ បញ្ជាក់ថា សំណង់សយ៉ាករបស់ ឈ្មោះ ទុន សារ៉ាង ចេញពីជញ្ជាំងផ្ទះរបស់ឈ្មោះឈន ម៉ាលី ធ្វើឱ្យបាំងបង្អួច បាំងខ្យល់ បាំងពន្លឺផ្ទះរបស់អ្នកស្រី ឈន ម៉ាលី ហើយជាសំណង់គ្មានច្បាប់អនុញ្ញាត និង ខុសពីលក្ខណៈនគរូបនិយបញ្ញត្តិទៀតផង ។

- យល់ឃើញថា ការដែលលោកមេធាវីចុងចម្លើយលើកឡើងនាពេលសវនាការនេះថា កូនក្តីរបស់លោក យល់ព្រមរុះរើយ៉ាបនេះចេញ ដោយរក្សាទុកតែ១ ,៥០ម ចំពីមុខទ្វាររបងអ្នកស្រី ទុន សារ៉ាង នោះ តុលាការកំពូល ដែលជំនុំជំរះលើកទី ១ តែលើអង្គច្បាប់ ពុំមានសមត្ថកិច្ចពិចារណាបានទេ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧៨០ ចុះថ្ងៃទី ២៦-១០-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី ចំពោះមុខគូភាគី**

១- ទទួលបណ្តឹងសាទុក្ខលេខ ៩៣៤ ចុះថ្ងៃទី ០១-១២-៩៩ របស់អ្នកស្រី ទុន សារ៉ាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៧៨០ ចុះថ្ងៃទី ២៦-១០-៩៩ របស់សាលាឧទ្ធរណ៍ ទុកជា

បានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០៛ ដែលអ្នកស្រី ទុន សារ៉ាង បានបង់ទុកជាមុនគឺ ៖

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,
- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ។